# សូមអាណិតរាស្ត្រផង!

យើងខ្ញុំជាខ្មែរ　　រស់ដោយសារស្រែ　　កេរពីដូនតា
ព្រលឹមទាល់យប់　　គ្មានឈប់ថ្ងៃណា　　ប្រឹងខំរក្សា
ដោយស្តាយទឹកដី ។

ញើសហូរដល់កែង　　ក្រោមថ្ងៃក្តៅហែង　　ដោយចិត្តភក្តី
ស្រឡាញ់គោរព　　នឹកគុណរាល់ថ្ងៃ　　គុណទឹកគុណដី
ផ្តល់កំណើតរស់ ។

អនិច្ចាក្រៃ　　រស់ដោយភិតភ័យ　　គ្មាក្តីអនុគ្រោះ
ជាងម្ភៃឆ្នាំហើយ　　រស់ដោយរងគ្រោះ　　អត់បាយដាច់ពោះ
ព្រោះពួកផ្តាច់ការ ។

ក្រុមមួយខ្ញុំចិន　　សម្លាប់បង្អិន　　គ្មានចិត្តមេត្តា
ចងចាប់សម្លាប់　　ក្រៅច្បាប់មាត្រា　　បាត់អស់សាសនា
ដែលខ្មែរគោរព ។

ក្រុមមួយខ្ញុំយួន　　រាល់ថ្ងៃរុកគួន　　មិនដែលនឹកឈប់
ក្បិចកលគ្រប់យ៉ាង　　ទន្ទ្រានសង្គ្រប់　　បំផ្លាញ់គ្មានឈប់
មនុស្សសត្វព្រឹក្សា ។

កាប់គាស់រំលំ　　លើងយកគល់ធំ　　ថ្មែលក់ទៅផ្សារ
ត្រីតូចត្រីធំ　　ដោយល្បិចឬស្បា　　ចាប់ចាក់ប្រហារ
ប្រាថ្នាបុណ្យយស ។

ពីចិតប្រាំបួន ល្បិចកលពួកយួន ដែលវាយសាបព្រួស
អោយខ្មែរបែកបាក់ ធ្លាក់ចូលក្នុងជ្រោះ មរណាស្ទើរអស់
គ្រោះជាតិប្រជា ។

ឆ្នាំកៅសិបបី ខ្មែរស្ទើយទុក្ខភ័យ ដោយបាត់ភ្នាក់ងារ
អន្តរជាតិសាសន៍ ចូលជួយពុះពារ អោយខ្មែរគ្រប់គ្នា
រើសអ្នកដឹកនាំ ។

រាស្ត្រខ្មែរចូលរួម ចិត្តកាយទាំងព្រម សាមគ្គីពូតផ្តុំ
ទោះពាលសាមាន្យ ចងចិត្តគំនុំ ល្បិចកល់បន្លំ
លបលួចប្រហារ ។

ក្រុមតស៊ូឈ្នះ សប្បាយចិត្តណាស់ ជួបជុំដូនតា
ស្បើយភ័យស្បើយព្រួយ រួចផុតទុក្ខា តែគួរអនិច្ចា
រងទុកថ្មីទៀត ។

ឆ្លតនឹងជោគជ័យ ភ្លេចជនអប្រិយ ប្រើគ្រប់ល្បិចស្នៀត
បញ្ឆេះសង្គ្រាម ឆេះភ្លាមស្លាប់ទៀត ក្រុមឈ្នះចោលម្សៀត
នាំគ្នាចោលស្រុក ។

បែកបាក់សាមគ្គី ពុករលួយស្រីញី វក់វីពេញស្រុក
ចូលជ្រកនឹងគេ ស្រវាយកសុខ លែងគិតសុខទុក្ខ
រាស្ត្រជាម្ចាស់ឆ្នោត ។

បោះឆ្នោតម្តងៗ ខិតខំបំពង សំឡេងបញ្ឆោត

អោយរាស្ត្រចូលរួម ក្នុងការបោះឆ្នោត រាស្ត្រខ្មែរល្ងង់ឆោត
បោះឆ្នោតឃ្លាតខ្ចី ។

ម្តងហើយម្តងទៀត មិនចោលមាយាទ បែកបាក់ទឹកដី
បាត់ទាំងធន់ធាន លើដីក្រោមដី ក្នុងទឹកគ្មានត្រី
រំលាយសូន្យសោះ ។

ល្អមហើយឬនៅ ចូរគិតមើលទៅ មេបក្សទាំងអស់
អាណិតរាស្ត្រផង ដែលធ្លាប់តែស្មោះ ចិត្តគិតស្រណោះ
ស្តាយទឹកស្តាយដី ។

ជាងសាមសិបឆ្នាំ ខ្មែររស់រងកម្ម សមល្មមហើយហ្ន៎
អាណិតរាស្ត្រផង រស់ក្នុងភិតភ័យ គ្មានជោគសេរី
ជួបតែក្តីទុក ។

ពួកលោកអ្នកឈ្នះ តែរាស្ត្រជាម្ចាស់ ចាញ់ជាប់ជួបទុក្ខ
លោកឈ្នះប៉ុណ្ណឹង លោកស្មានថាសុខ តែរាស្ត្រជាប់គុក
សុខតែពួកលោក ។

វេលាដល់ហើយ បោះឆ្នោតលើកក្រោយ បើរួមបានជោគ
ឈ្នះទាំងអស់គ្នា ទាំងរាស្ត្រទាំងលោក រួចផុតទុក្ខសោក
ប្រុសស្រ្តីក្មេងចាស់ ។

ក្បែរមក្សានស្រុកទេស ត្រូវកុំប្រហែស រួបរួមជាក់ច្បាស់
ថ្កើងថ្កានឧត្តម សមរម្យជាម្ចាស់ ភ្លឺថ្លាស្រទ្បះ

ជាម្ចាស់ទឹកដី ។

ដូចនេះត្រូវលះ អស្មិមានះ ត្រូវចេះខ្នាតខ្មី

ត្រូវប្រុងប្រយ័ត្ន បង្ការគ្រោះភ័យ កសាងទឹកដី

ខ្មែរសុខសាន្តអើយ ។